រាជបណ្ឌិត្យសភាកម្ពុជា

# យុត្តិធម៌ក្នុងប្រព័ន្ធតុលាការកម្ពុជា
# (២០១៣-២០២២)

## Justice in Cambodian Judicial System
## (2013-2022)

ខេង សុវណ្ណតារា

សារណាបរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : វិទ្យាសាស្ត្រនយោបាយ

ឆ្នាំ ២០២៣

**រាជបណ្ឌិត្យសភាកម្ពុជា**

៙៙📖៚៚

# យុត្តិធម៌ក្នុងប្រព័ន្ធតុលាការកម្ពុជា
# (២០១៣-២០២២)

## Justice in Cambodian Judicial System
## (2013-2022)

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ 00127 01
រាជបណ្ឌិត្យសភាកម្ពុជា

**ខេង សុវណ្ណតារា**

**គ្រូណែនាំ : បណ្ឌិត ភា ម៉ាឌុល**

**សារណាបរិញ្ញាបត្រជាន់ខ្ពស់**
**ជំនាញ : វិទ្យាសាស្ត្រនយោបាយ**

**ភ្នំពេញ ២០២៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ : ០២៤ / ២៣ ស.ស.រ.

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យការពារបញ្ចប់សារណា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ១២៤ អនក.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១១ ស.ស.រ. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្របង់ថ្លៃសិក្សាស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងគោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងចំណារឯកភាពរបស់គ្រូណែនាំចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យលោក **ខេង សុវណ្ណតារា** និស្សិត **ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៥ វគ្គ១** ជំនាញ **វិទ្យាសាស្ត្រនយោបាយ** ការពារបញ្ចប់សារណានៅថ្ងៃទី១៧ខែកញ្ញាឆ្នាំ២០២៣

**ប្រការ ២** : គណៈកម្មការវាយតម្លៃសារណា មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ៥កើត ខែ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែសីហា ឆ្នាំ២០២៣

ប្រធាន

បណ្ឌិតសភាចារ្យ **សុខ ទូច**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ : ០៤៨ / ២៣ ឧ.ឧ.ឧ.

# លិខិតឧទ្ទេសនាម
## គណៈកម្មការវាយតម្លៃការការពារបញ្ចប់សារណា
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ. | គោត្តនាម និង នាម | ជំនាញ | តួនាទី |
|---|---|---|---|
| ១ | បណ្ឌិត **គិន ភា** | វិទ្យាសាស្ត្រនយោបាយ | ប្រធាន |
| ២ | បណ្ឌិត **ខែក ធីរៈ** | វិទ្យាសាស្ត្រនយោបាយ | គ្រូវាយតម្លៃទី១ |
| ៣ | បណ្ឌិត **ស៊ឹន សំ** | វិទ្យាសាស្ត្រនយោបាយ | គ្រូវាយតម្លៃទី២ |
| ៤ | បណ្ឌិត **តូច សុធារី** | វិទ្យាសាស្ត្រនយោបាយ | គ្រូវាយតម្លៃទី៣ |
| ៥ | បណ្ឌិត **ភា ម៉ាឌុល** | វិទ្យាសាស្ត្រនយោបាយ | គ្រូណែនាំ |

- និស្សិត : **ខេង សុវណ្ណតារា** - **ភេទ : ប្រុស**
- ជំនាញ : **វិទ្យាសាស្ត្រនយោបាយ** - **ជំនាន់ទី៥ វគ្គ១**
- ប្រធានបទ : **យុត្តិធម៌ក្នុងប្រព័ន្ធតុលាការកម្ពុជា (២០១៣-២០២៣)**
- គ្រូណែនាំ : បណ្ឌិត **ភា ម៉ាឌុល**
- កាលបរិច្ឆេទការពារ : ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០២៣ - ម៉ោង : ៩:០០ ព្រឹក

ថ្ងៃ ចន្ទ ៤ កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២៣
ប្រធាន

**ចំណាំ :**
-គណៈកម្មការ និងនិស្សិត(ប្រុស) ស្លៀកបំពាក់អាវធំ
-គណៈកម្មការ និងនិស្សិត(នារី) ស្លៀកបំពាក់ប្រពៃណី ឬអាវធំ

បណ្ឌិតសភាចារ្យ **សុខ ទូច**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការវាយតម្លៃសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**សូមបញ្ជាក់ថា៖** លោក **ខេង សុវណ្ណតារា** និស្សិតជំនាន់ទី៥ វគ្គ១ ជំនាញ វិទ្យាសាស្ត្រនយោបាយ ពិតជាបានការពារសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើប្រធានបទ «**យុត្តិធម៌ក្នុងប្រព័ន្ធតុលាការកម្ពុជា (២០១៣-២០២២)**» បញ្ចប់ដោយជោគជ័យ នៅថ្ងៃទី**១៧** ខែកញ្ញា ឆ្នាំ២០២៣ ប្រាជ្ញកមែន។

| | | |
|---|---|---|
| **១.** | បណ្ឌិត **គិន ភា** | **ប្រធាន** |
| **២.** | បណ្ឌិត **ខែក ធីរៈ** | **គ្រូវាយតម្លៃទី១** |
| **៣.** | បណ្ឌិត **ស៊ីន ស៊ុំ** | **គ្រូវាយតម្លៃទី២** |
| **៤.** | បណ្ឌិត **តូច សុធារី** | **គ្រូវាយតម្លៃទី៣** |
| **៥.** | បណ្ឌិត **ភា ម៉ាធុល** | **គ្រូណែនាំ** |

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

**អគ្គលេខាធិការរង**
**ទទួលបន្ទុកមជ្ឈមណ្ឌលបណ្តុះបណ្តាល និង ស្រាវជ្រាវ**

**ស៊ូត្រ សំណាង**

# មាតិកា

ឧទ្ទិសស្លាដៃ ........ i
សេចក្តីថ្លែងអំណរគុណ ........ ii
អំណះអំណាង ........ iii
មូលន័យសង្ខេប ........ iv
Abstract........ v
អារម្ភកថា ........ vi

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣
៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៤
៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៤

## ជំពូកទី១

## ទស្សនៈស្តីពីយុត្តិធម៌

១.១.លក្ខណៈទូទៅនៃយុត្តិធម៌សង្គម ........ ៥
១.២.សញ្ញាណនៃយុត្តិធ៌ក្នុងសង្គម ........ ៧
១.៣.ទ្រឹស្តីស្តីពីការបែងចែកអំណាច និង ច្បាប់ ........ ១០
១.៣.១.ទស្សនៈលោក John Lock........ ១១
១.៣.២.ទស្សនៈលោក Montesquieu ........ ១២
១.៤.ការបែងចែកអំណាចនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ........ ១៣
១.៥.ប្រវត្តិតុលាការកម្ពុជា........ ២០
១.៥.១.សម័យបុរាណដល់ឆ្នាំ១៨៦៣ ........ ២១
១.៥.២.សម័យអាណានិគមឆ្នាំ១៨៦៣-១៩៥៣ ........ ២១

១.៥.៣.ប្រព័ន្ធតុលាការឆ្នាំ១៩៥៣-១៩៩៣ ........ ២២
១.៥.៤.កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ........ ២៦

## ជំពូកទី២

## ការគ្រប់គ្រងប្រព័ន្ធតុលាការកម្ពុជា

**២.១.អំណាចតុលាការ** ........ ៣១
**២.២.ការរៀបចំអង្គការតុលាការ** ........ ៣៣
២.២.១.សាលាដំបូង និង អយ្យការអមសាលាដំបូង ........ ៣៦
ក.សាលាដំបូង ........ ៣៦
ក.១.ការរៀបចំ និង ការប្រព្រឹត្តទៅនៃសាលាដំបូង ........ ៣៧
ក.២.សមត្ថកិច្ច ........ ៣៨
ខ.អយ្យការអមសាលាដំបូង ........ ៤១
គ.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ........ ៤២
២.២.២.សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍ ........ ៤៣
ក.សាលាឧទ្ធរណ៍ ........ ៤៣
ក.១.ការរៀបចំ និង ការប្រព្រឹត្តទៅនៃសាលាឧទ្ធរណ៍ ........ ៤៣
ក.២.សមត្ថកិច្ច ........ ៤៤
ខ.មហាអយ្យការអមសាលាឧទ្ធរណ៍ ........ ៤៦
គ.អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ........ ៤៨
២.២.៣.តុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល ........ ៤៩
ក.តុលាការកំពូល ........ ៤៩
ក.១.ការរៀបចំ និង ការប្រព្រឹត្តទៅនៃសាលាកំពូល ........ ៤៩
ក.២.សមត្ថកិច្ច ........ ៥០
ខ.មហាអយ្យការអមតុលាការកំពូល ........ ៥២
គ.អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាកាកំពូល ........ ៥៣
២.២.៤.វិសមិតភាព ........ ៥៤
២.២.៥.ថវិការសាលាជម្រះក្តី និង អយ្យការអមសាលាជម្រះក្តី ........ ៥៥

**២.៣. តួអង្គសំខាន់ៗក្នុងស្ថាប័នតុលាការ**......................................................៥៦
២.៣.១.ចៅក្រម......................................................................................៥៦
២.៣.២.ព្រះរាជអាជ្ញា ..................................................................................៦២
**២.៤.ស្ថាប័នពិនិត្យតាមដាន និង ជួយសម្រួលដល់ស្ថាប័នតុលាការ**..............៦៤
២.៤.១.ក្រសួងយុត្តិធម៌..............................................................................៦៤
២.៤.២.ក្រុមប្រឹក្សាជម្មនុញ្ញ ........................................................................៦៥
ក.ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជម្មនុញ្ញ .........,......................៦៦
ខ.សមត្ថកិច្ចនៃក្រុមប្រឹក្សាជម្មនុញ្ញ.......................................................... ៧០
២.៤.៣.ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម...........................................................៧២
ក.ការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ....................៧២
ខ.សមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃអង្គចៅក្រម............................................... ៧៦

## ជំពូកទី៣

## ភាពនុវត្តភាព ការប្រឈម និង ដំណោះស្រាយ

**៣.១.ភាពនុវត្តភាព**..................................................................................៨០
៣.១.១.ការប្រឈមខាងក្រៅ..........................................................................៨៥
ក.ការអន្តរាគមន៍ ..................................................................................៩០
ខ.សម្ពាធពីអ្នកនយោបាយ .......................................................................៩១
គ.សម្ពាធពីអន្តរជាតិ.............................................................................៩៥
៣.១.២.ការប្រឈមខាងក្នុង ........................................................................ ៩៧
ក.ការកកស្ទះសំណុំរឿងក្តី .......................................................................៩៨
ខ.អំពើពុករលួយជាប្រព័ន្ធ.....................................................................១០០
**៣.២ ដំណោះស្រាយ** .............................................................................. ១០៣
**សន្និដ្ឋាន**...........................................................................................១០៦
**គន្ធនិទ្ទេស**........................................................................................ ១០៧
**ឧបសម្ព័ន្ធ**

# មូលន័យសង្ខេប

សញ្ញាណនៃការបែងចែកអំណាចឲ្យដាច់ស្រលះពីគ្នា ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញខ្មែរជាលើកដំបូងក្នុងរដ្ឋធម្មនុញ្ញទី១ឆ្នាំ១៩៤៧ ហូតមកដល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។ក្នុងគោលបំណងធានាមិនឲ្យការរំលោភអំណាចនៅក្នុងសង្គមកម្ពុជា លើសពីនេះទៀត វាក៏បានកំណត់យ៉ាងច្បាស់ពីតួនាទីនៃអំណាចនីមួយៗផងដែរដូចជាអំណាចបញ្ញត្តិច្បាប់ អំណាចប្រតិបត្តិច្បាប់និង អំណាចតុលាការ ដើម្បីបញ្ចៀសកុំឲ្យមានអំណាចផ្តាច់ការរបស់បុគ្គលណាម្នាក់នៅក្នុងសង្គមកម្ពុជា និង ធានាឲ្យមានការរីកលូតលាស់នៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាផងដែរ។

ទោះជាបែបនេះក្តី ក្រោយឆ្នាំ១៩៩៣ អំណាចកំពូលទាំងបី ត្រូវបានមើលឃើញថា មិនទាន់អនុវត្តបានល្អប្រសើរដូចបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣នោះទេ។ ប្រជាពលរដ្ឋ តែងតែទទួលរងនូវភាពអយុត្តិធម៌សង្គម ការរំលោភបំពានសិទ្ធិសេរីភាពឯកជន ការចាប់ខ្លួនគ្មានដីការបស់តុលាការឃុំខ្លួនលើសពេលកំណត់ជាដើម។លើសពីនេះទៀតសកម្មជននយោបាយ ឬ អ្នកនយោបាយតែងតែត្រូវបានចាប់ខ្លួនដោយអំណាចតុលាការ និងមានពេលខ្លះទៀត ប្រតិកម្មរបស់អ្នកមានអំណាចក្នុងសង្គមកម្ពុជា ទៅលើស្ថាប័នតុលាការ បែបជាទទួលបានជោគជ័យ ច្រើនទៅវិញហាក់ដូចជាអំណាចតុលាការកំពុងស្ថិតនៅក្រោមការបង្គាប់បញ្ជាពីស្ថាប័ននយោបាយទៅវិញ។

បញ្ហាទាំងអស់នេះហើយ ដែលបានទាមទារឲ្យមានការធ្វើកំណែទម្រង់ជាបន្ទាន់ទៅលើច្បាប់និងប្រព័ន្ធយុត្តិធម៌។ ជាលទ្ធផល មានការអនុម័តច្បាប់មួយចំនួនពាក់នឹងស្ថាប័នតុលាការ មានការបណ្តុះបណ្តាលមន្ត្រីតុលាការ និងមានការតំឡើងបៀវត្ស និង ប្រាក់ពេលសវនាការជាដើម។ លើសពីនេះទៀត មានការបង្កើតសាលាឧទ្ធរណ៍តំបន់សាលាដំបូងខេត្តកែប និង អយ្យការអមខេត្តកែប ដើម្បីរួមចំណែកកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ។

ទទឹមនឹងការយកចិត្តទុកដាក់ធ្វើកំណែទម្រង់លើច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ផលអវិជ្ជមានខ្លះនៅតែកើតមានឡើង ដូចជានីតិវិធីក្នុងពេលសវនាការ ការឃុំខ្លួនហួសពេលកំណត់ដោយច្បាប់ ប្រតិកម្មរបស់អ្នកមានអំណាចទៅលើស្ថាប័នតុលាការ ការផ្អើបសំណុំរឿងក្តីខ្លះ ការកក់ស្ទះសំណុំរឿងក្តី ហាក់គ្មានចំណាត់ការឲ្យមានប្រសិទ្ធិភាព ជាដើម។

ទោះជាយ៉ាណាក៏ដោយ យុត្តិធម៌នៅសង្គមកម្ពុជា(២០១៣-២២២)នៅតែមានលក្ខណៈតូចចង្អៀតនៅឡើយទេនេះក៏ព្រោះតែអំណាចនៃស្ថាប័ននីតិប្រតិបត្តិតែងតែមានឥទ្ធិពលទៅលើស្ថាប័នតុលាការតាមគ្រប់រូបភាព មានពេលខ្លះ ការប្រតិកម្មជាសាធារណៈ មានពេលខ្លះតាមរយៈ សមាជិករាជរដ្ឋាភិបាល។ ដូច្នេះដើម្បីធានាឲ្យបាននូវឯករាជ្យភាពនៃការសម្រេចចិត្តរបស់អ្នកអនុវត្តច្បាប់នៅក្នុងស្ថាប័នតុលាការស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែមានឯករាជ្យភាពរបស់ខ្លួនជាមុនសិនមានន័យថាសមាសភាពក្នុងការគ្រប់គ្រងស្ថាប័នមួយមិនមែនជាសមាជិករាជរដ្ឋាភិបាលត្រូវតែជាបុគ្គលឯករាជ្យទាំងស្មារតីនឹងមានឆន្ទៈគោរព និង អនុវត្តច្បាប់ដើម្បីយុត្តិធម៌ក្នុងសង្គមកម្ពុជា។